**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ÷ ០០២ ដនស/អរប/នរប/រដា

ថ្ងៃសុក្រ ១១ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨

# របាយការណ៍បូកសរុបលទ្ធផល នៃការអនុវត្តការងារឆ្នាំ ២០១៧ និងលើកទិសដៅការងារឆ្នាំ ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សេចក្តីផ្តើម

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រក្សាបាននូវខឿនការពារប្រទេស សន្តិសុខជាតិ ការពារអធិបតេយ្យ ធានាស្ថិរភាពនយោបាយ ស្ថិរភាពសេដ្ឋកិច្ច-សង្គម ដោយសម្រេចបានជោគជ័យយ៉ាងធំធេងក្នុងការបន្តជំរុញការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ នាំមកនូវកិត្យានុភាពជាតិទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ។ ក្នុងការរួមចំណែកអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបានការងារធំៗជាច្រើនលើវិស័យការងារដីធ្លី និងសំណង់ ដូចជា ការផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋដែលក្រីក្រនិងខ្វះដី ការផ្តល់ដីនិងសាងសង់ផ្ទះជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ គ្រួសារយោធិន និងនគរបាលនៅតាមបណ្តោយព្រំដែន ការជំរុញសាងសង់លំនៅឋានមានតម្លៃសមរម្យ ដែលជាការបង្កលក្ខណៈ និងលើកកម្ពស់សិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ប្រជាពលរដ្ឋមានចំណូលមធ្យម ប្រាក់ចំណូលទាប និងជនងាយរងគ្រោះ ការកាត់បន្ថយនិងទប់ស្កាត់វិវាទដីធ្លី ការពង្រឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី តាមរយៈការពន្លឿនការចុះបញ្ជីដីជូនប្រជាពលរដ្ឋ ការចុះបញ្ជីដីរដ្ឋ និងដីសហគមន៍ជនជាតិដើមភាគតិច ដែលទាំងនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីស្រទាប់មហាជនទូទៅ។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋានប្រកបដោយចីរភាព និងនិរន្តរភាពបរិស្ថាន និងធនធានធម្មជាតិ តាមរយៈការគាំទ្របច្ចេកទេសក្នុងការរៀបចំផែនការរៀបចំដែនដី ផែនការប្រើប្រាស់ដី និងប្លង់គោលប្រើប្រាស់ដីដោយចាប់ផ្តើមពីតំបន់អាទិភាព ទីក្រុង ទីប្រជុំជន និងតំបន់ឆ្នេរសមុទ្រ។



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

## I-លទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧

### ១-ការងារអភិវឌ្ឍស្ថាប័ន

#### ១.១- ការងារគ្រប់គ្រងមន្ត្រី

ក្រសួងមានមន្ត្រីរាជការសរុបចំនួន **៣ ១៩៣** នាក់ (ស្ត្រី ៥៣០ នាក់) ក្នុងនោះថ្នាក់កណ្តាលមានចំនួន **៧៥២** នាក់ (ស្ត្រី ១៥៣ នាក់) ថ្នាក់មន្ទីរមានចំនួន **១ ១១២** នាក់ (ស្ត្រី ២៣៩ នាក់) ថ្នាក់ការិយាល័យភូមិបាលក្រុង ស្រុក ខណ្ឌ មានចំនួន **១ ៣២៩** នាក់ (ស្ត្រី ១៣៨ នាក់) ក្នុងនោះមានមន្ត្រីជាជនពិការចំនួន **៣៩** នាក់ (ស្ត្រី ០៦ នាក់)។ ក្នុងចំណោមមន្ត្រីរាជការជាស្ត្រីទាំង **៥៣០** នាក់ មានមុខតំណែងចាប់ពីរដ្ឋលេខាធិការរហូតដល់ថ្នាក់អនុការិយាល័យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានចំនួន **១៨៣** នាក់ ស្មើនឹង ៣៥ % នៃចំនួនមន្ត្រីរាជការជាស្ត្រីសរុប។

លទ្ធផលក្នុងឆ្នាំ ២០១៧ សម្រេចបាន÷

- ដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការក្រសួង ចំនួន **៣០៤** នាក់
- ដំឡើងឋានៈ តែងតាំងមុខតំណែង ប្រគល់ភារកិច្ច សម្រួលភារកិច្ចដល់មន្ត្រីរាជការសរុបចំនួន **៦៨** នាក់ (ស្ត្រី **១៥** នាក់)
- ផ្តល់នីត្យានុកូលភាពដល់ការតែងតាំងមុខតំណែង ប្រគល់ភារកិច្ច និងផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សរុបចំនួន **៦៤** នាក់ (ស្ត្រី ០៣ នាក់) និងធ្វើលិខិតបដិសេធចំនួន ០៨ នាក់
- ផ្ទេរមន្ត្រីរាជការបញ្ចូលក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន **១៨** នាក់ (ស្ត្រី ០៨ នាក់) និងបានផ្ទេរមន្ត្រីរាជការចេញពីក្របខណ្ឌក្រសួង ចំនួន ០៤ នាក់
- រៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មី ឆ្នាំ ២០១៧ ចំនួន **៦២** នាក់ (ស្ត្រី ០៦ នាក់)
- ដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន **៣២** នាក់ (ស្ត្រី ០៣ នាក់) និងលុបឈ្មោះចេញពីក្របខណ្ឌចំនួន **២០** នាក់
- អនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន ០៥ នាក់ ឈប់សម្រាកលំហែមាតុភាពចំនួន **០៦** នាក់ និងអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកពីការងារចំនួន **១៦** នាក់
- អនុញ្ញាតឱ្យមន្ត្រីរាជការ ចំនួន ០៩ នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល
- អនុញ្ញាតឱ្យមន្ត្រីកម្មសិក្សាការីចុះធ្វើកម្មសិក្សា និងហាត់ការងារចំនួន **១៦** នាក់។

#### ១.២- ការងារផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច

##### ក- ការងារគាំទ្រដល់ការអនុវត្តថវិកាកម្មវិធី

- បានបង្កើតអង្គភាពថវិកាដល់កម្រិតអនុកម្មវិធីក្នុងគោលដៅ ដើម្បីធានាបាននូវភាពជាម្ចាស់នៃ

ការគ្រប់គ្រង និងប្រើប្រាស់ថវិកាឱ្យសម្រេចបាននូវសូចនាករដែលបានកំណត់ និងកាត់បន្ថយពេលវេលាក្នុងការពិនិត្យសម្រេច និងលើកសំណើសុំថវិកា

- បានធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយបានជម្រះបញ្ជីលើទ្រព្យសម្បត្តិដែលចាស់ទ្រុឌទ្រោម។

ខ-ការងារចំណូល

ក្រសួងបានប្រមូលចំណូលចូលថវិកាជាតិសរុបមានចំនួន **៣៧១ ៩០៩ ៧៧១ ៩១៦** រៀល គិតទាំងចំណូលពីការផ្ទេរអចលនទ្រព្យរួមមាន÷

១-ចំណូលពីសេវាសុរិយោដីមានចំនួន **៤២ ៤៧១ ១៥៨ ១១៥** រៀល ក្នុងនោះ÷

- ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ចំនួន **៦ ៦៥៥ ៨៣៤ ៩៣៥** រៀល
- ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ចំនួន ៣៥ ៨១៥ ៣២៣ ១៨០ រៀល

២-ចំណូលពីសេវាសំណង់ មានចំនួន **១៤ ០៦៦ ១៩៨ ៧០៨** រៀល

- សេវាសំណង់ ៩ ៥០៨ ១៩៨ ៧០៨ រៀល
- សេវាពីការសាងសង់លើសសន្ទស្សន៍ប្រើប្រាស់ដី ៤ ៥៥៨ ០០០ ០០០ រៀល

៣-ចំណូលពីការជួលទីតាំងរោងចក្រ សហគ្រាស មានចំនួន **២៧៧ ០៣៦ ០៩០** រៀល

៤-ចំណូលពីពន្ធលើការផ្ទេរអចលនទ្រព្យ ដែលប្រមូលនៅអង្គភាពពន្ធដារ បានចំនួន **៣១៥ ០៩៥ ៣៧៩ ០០៣** រៀល។

## ១.៣. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំផ្សព្វផ្សាយ

- បានបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងវគ្គផ្សព្វផ្សាយពាក់ព័ន្ធនឹងជំនាញការងាររបស់ក្រសួង ចំនួន **៧៦** វគ្គ សិក្ខាកាមសរុប **៨ ១៦០** នាក់ (ស្ត្រី ១ ៩៣៥ នាក់) ក្នុងនោះ÷
  - ថ្នាក់ពិសេសមធ្យមសុរិយោដីជំនាន់ទី ៨ **០១** វគ្គ សិក្ខាកាមសរុប **៣៦** នាក់
  - គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យដីធ្លី **០៨** វគ្គ សិក្ខាកាមសរុប **៩៣៥** នាក់
  - ការងារសុរិយោដី **១០** វគ្គ សិក្ខាកាមសរុប **៨៤៧** នាក់
  - ការងារសំណង់ **០៧** វគ្គ សិក្ខាកាមសរុប **៥៧៨** នាក់
  - គណៈស្ថាបត្យករ ០១ វគ្គ សិក្ខាកាមសរុប **២៥៦** នាក់
  - ការងាររៀបចំដែនដីនិងនគរូបនីយកម្ម ០៨ វគ្គ សិក្ខាកាមសរុប **៤៤៩** នាក់
  - ការងារលំនៅឋាន **១៥** វគ្គ សិក្ខាកាមសរុប **២ ៣៣១** នាក់

- សេវាសាធារណៈ ០៥ វគ្គ សិក្ខាកាមសរុប ៦៩៩ នាក់
- ការពង្រឹងសមត្ថភាពគ្រប់គ្រងទិន្នន័យ ០២ វគ្គ សិក្ខាកាមសរុប ៣២៧ នាក់
- ការងារផែនការថវិកា ០៦ វគ្គ សិក្ខាកាមសរុប ៦២៩ នាក់
- ការងារយេនឌ័រ ១៣ វគ្គ សិក្ខាកាមសរុប ១ ០៧៣ នាក់

– បានចុះផ្សព្វផ្សាយខិតប័ណ្ណ ស្ដីពីសុវត្ថិភាពនៃការកាន់កាប់ដីធ្លី បន្ទាប់ពីការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី បានចំនួន ៥ ០០០ សន្លឹក

– បានបញ្ជូនមន្ត្រីចូលរួមជាសមាជិកនៃគណៈកម្មាធិការ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានាក្នុង និងក្រៅប្រទេសចំនួន ២៤១ នាក់។

## ១.៤-ការងារសវនកម្ម

– ចុះធ្វើសវនកម្មបានចំនួន ២៨ អង្គភាព គឺនៅអង្គភាពថ្នាក់កណ្តាល ០៣ អង្គភាព និងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ២៥ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ចំនួន ៦០

– បានចុះពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន ១០ គឺខេត្តបន្ទាយមានជ័យ ប៉ៃលិន មណ្ឌលគិរី ត្បូងឃ្មុំ បាត់ដំបង កំពង់ឆ្នាំង ស្ទឹងត្រែង រតនគិរី កោះកុង និងខេត្តព្រះសីហនុ។

## ១.៥-ការងារអធិការកិច្ច

– បានចុះត្រួតពិនិត្យការងារបច្ចេកទេសសុរិយោដីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន ២៤ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ចំនួន ៩៦ ដែលមន្ត្រីចូលរួមទទួលបានការណែនាំសរុបចំនួន ៤១៥ នាក់ (ស្ត្រី ៨២ នាក់)

– បានចុះត្រួតពិនិត្យដំណើរការការងាររដ្ឋបាល និងការផ្តល់សេវាសាធារណៈនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីចំនួន ២៤ រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល សរុបចំនួន ៩០ ក្រុង ស្រុក ខណ្ឌ

– បានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងមន្ត្រី និងការងារបច្ចេកទេសសុរិយោដី ព្រមទាំងវិវាទដីធ្លីផ្សេងៗទៀតសរុបចំនួន ១១០ ករណី ក្នុងនោះបានដោះស្រាយបញ្ចប់ចំនួន ១៨ ករណី បង្វែរសំណុំរឿងទៅសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបន្ត ចំនួន ២០ ករណី និងកំពុងចុះពិនិត្យស្រាវជ្រាវចំនួន ៧២ ករណី។

- បានធ្វើលិខិតដើម្បីសុំអន្តរាគមន៍ពីសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជំរុញដល់រដ្ឋបាលរាជធានី ខេត្ត ពន្លឿនការដោះស្រាយវិវាទក្នុងដែនសមត្ថកិច្ចរាជធានី ខេត្ត។

### ១.៦- ការគាំទ្រការងារវិមជ្ឈការ និងវិសហមជ្ឈការ

- បាននិងកំពុងសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្នុងការបន្តអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញ ចូលតែមួយ ទាំង ៥២ក្រុង ស្រុក ខណ្ឌ
- បានបញ្ចប់របាយការណ៍បញ្ជីវិភាគមុខងារជូនគ.ជ.អ.ប.
- បានពិនិត្យកែសម្រួលមុខសញ្ញា និងតម្លៃសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បាននិងកំពុងសហការជាមួយអគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងការប្រមូលពន្ធប្រថាប់ត្រាពីការផ្ទេរកម្មសិទ្ធិ និងការចុះបញ្ជីដំបូង
- បាននិងកំពុងសហការជាមួយរដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ។

## ២- ការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ក. ក្របខណ្ឌគោលនយោបាយនិងក្របខណ្ឌគតិយុត្តចូលជាធរមាន

- បានទទួលការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ដែលបានសហការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

ខ. ក្របខណ្ឌគោលនយោបាយនិងក្របខណ្ឌគតិយុត្តកំពុងរៀបចំ÷

### ខ.១. ការងាររៀបចំដែនដី និងនគរូបនីយកម្ម

- ច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម
- អនុក្រឹត្យស្តីពីការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ប្រកាសស្តីពីការកំណត់ផ្លាកម្លាតអប្បបរមារបស់អគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់
- ប្រកាសអន្តរក្រសួងស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនគរូបនីយកម្ម និងសំណង់
- ប្រកាសស្តីពីការអភិវឌ្ឍដី
- ប្រកាសស្តីពីការអភិវឌ្ឍបុរី

- សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តនូវផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ បណ្តាញប្រភពទឹក និងទីតាំងព្រលានយន្តហោះនៅលើកោះរ៉ុង ក្រុងព្រះសីហនុ
- សារាចរណែនាំស្តីពីការចាត់វិធានការផ្សព្វផ្សាយទប់ស្កាត់ការសាងសង់ផ្ទះបណ្តែតទឹក និងផ្ទះតាមដីចំណីទន្លេ បឹង ស្ទឹង ព្រែក អូរ
- បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**១.២. ការងារសំណង់**

- ច្បាប់ស្តីពីសំណង់
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ
- ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ប្រកាសស្តីពីការគ្រប់គ្រងការប្រកបអាជីវកម្មមន្ទីរពិសោធន៍ពាក់ព័ន្ធនឹងសំណង់អគារ។

**១.៣. ការងារលំនៅឋាន**

- សេចក្តីណែនាំលើការអនុវត្តស្តីពីការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ
- ដំណើរការនៃការដាក់ពាក្យស្នើសុំទិញលំនៅឋានតម្លៃសមរម្យ
- លក្ខខណ្ឌក្រោយការទិញលំនៅឋានតម្លៃសមរម្យ
- កិច្ចសន្យាទិញ លក់លំនៅឋានតម្លៃសមរម្យ
- ភតិសន្យាលំនៅឋានតម្លៃសមរម្យ
- បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រង និងប្រើប្រាស់ក្នុងអគារសហកម្មសិទ្ធិនៃលំនៅឋានតម្លៃសមរម្យ។

**១.៤. ការងារមន្ទីរពិសោធន៍**

- ប្រកាសស្តីពីការគ្រប់គ្រងមន្ទីរពិសោធន៍សំណង់
- ប្រកាសស្តីពីការបញ្ជាក់សម្ភារ បរិក្ខារ និងផលិតផលសំណង់
- ប្រកាសស្តីពីត្រួតពិនិត្យលទ្ធផលពិសោធន៍
- ភ្នាក់ងារក្នុងការចេញលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់។

**៣-ការផ្តល់សេវាសាធារណៈតាមច្រកចេញ ចូលតែមួយ**

- គម្រោងស្នើសុំសរុបចំនួន **១៣៨ ២៧៦** គម្រោង ក្នុងនោះថ្នាក់ក្រសួងមាន **៨២៧** គម្រោង និងថ្នាក់រាជធានី ខេត្ត មាន **១៣៧ ៤៤៩** គម្រោង និងគម្រោងស្នើសុំដែលនៅសល់ពីឆ្នាំចាស់ចំនួន**២៩៧** គម្រោង

- គម្រោងដែលបានអនុញ្ញាតរួចមានចំនួន **១៣៨ ៥៧៣** គម្រោង ក្នុងនោះថ្នាក់ក្រសួងមាន ៨១៤ គម្រោង និងថ្នាក់រាជធានី ខេត្ត មានចំនួន **១៣៧ ៧៥៩** គម្រោង
- ចំណូលទទួលបានពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ មានចំនួនសរុប **៥៦ ៥៣៧ ៣៥៦ ៨២៣** រៀល រួមមានសេវានៅថ្នាក់កណ្តាលមានចំនួន **១០ ០៤០ ៦៩២ ៧២៨** រៀល និងថ្នាក់រាជធានី ខេត្តមានចំនួន **៤៦ ៤៩៦ ៦៦៤ ០៩៥** រៀល។

## ៤-ការងាររដ្ឋបាលដីធ្លី

### ៤.១.ការងារសុរិយោដី

ក. ការងារចុះបញ្ជីដំបូង

ក្រសួងបានចេញប័ណ្ណកម្មសិទ្ធិដីបានចំនួន **២៣៧ ១៤៣** ប័ណ្ណ ក្នុងនោះចែកប័ណ្ណដល់ដៃប្រជាពលរដ្ឋបាន **២០៩ ៦៧៩** ប័ណ្ណ រួមមាន÷

- **កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ÷** បានប្រកាសកំណត់តំបន់វិនិច្ឆ័យចំនួន **២៣៨** ភូមិ បញ្ចូលទិន្នន័យចំនួន **២៨៧ ០៧៧** ក្បាលដី ចេញប័ណ្ណបានចំនួន **២២៩ ៥៧៨** ប័ណ្ណ និងចែកប័ណ្ណជូនប្រជាពលរដ្ឋបានមានចំនួន **២០២ ១១៤** ប័ណ្ណ
- **ការចុះបញ្ជីដីតាមបទបញ្ជាលេខ ០១ ប.ប.** សម្រេចចែកប័ណ្ណបាន **៤ ៤៩៣** ប័ណ្ណ
- **ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ** សម្រេចបាន **៣ ០១២** ប័ណ្ណ ក្នុងនោះការចុះបញ្ជីដីរដ្ឋបាន **៧០០** ប័ណ្ណ
- **ការចុះបញ្ជីដីសម្ហូហភាពសហគមន៍ជនជាតិដើមភាគតិច** សម្រេចបាន **៦០** ប័ណ្ណ សម្រាប់ ០៥ សហគមន៍។

សរុបលទ្ធផលពីពេលចាប់ផ្តើមអនុវត្តរហូតដំណាច់ឆ្នាំ ២០១៧ ក្រសួងចេញប័ណ្ណកម្មសិទ្ធិដីបានចំនួន ៤ ៨៨១ ៥៨២ ប័ណ្ណ ក្នុងនោះចែកប័ណ្ណជូនប្រជាពលរដ្ឋបានចំនួន **៤ ៦៤៧ ៨៨៦** ប័ណ្ណ ស្មើនឹង **៦៦,៤ %** នៃក្បាលដីប៉ាន់ស្មានសរុប **៧** លានក្បាលដី។ លទ្ធផលនេះ បើគិតធៀបតាមផែនការដែលត្រូវសម្រេចក្នុងឆ្នាំ ២០១៧ ឃើញថាលើសផែនការ 0,៤%មានដូចខាងក្រោម÷

- **ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ** សម្រេចបាន **៣ ៦២៦ ១៥៨** ប័ណ្ណ
- **ការចុះបញ្ជីដីតាមបទបញ្ជាលេខ ០១ប.ប** សម្រេចបាន **៦៤១ ៦២៣** ប័ណ្ណ
- **ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ** សម្រេចបាន **៦១៣ ២៨២**ប័ណ្ណ
- **ការចុះបញ្ជីដីសម្ហូហភាពសហគមន៍ជនជាតិដើមភាគតិច** សម្រេចបាន **១៩** សហគមន៍ ស្មើនឹង **៥១៩** ប័ណ្ណទំហំ **១៦ ២៧១** ហិកតា ស្មើ **១ ៧៨៤** គ្រួសារ។

ខ- ការងារចុះបញ្ជីបន្ត

- ចុះបញ្ជីសិទ្ធិជួលរយៈពេលវែង បានចំនួន ៤៣ ប័ណ្ណ ស្មើនឹង ៦ ៥៣៤ ហិកតា ៥៥ អា ២៦ ស
- ចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច បានចំនួន ២៤ ប័ណ្ណ ស្មើនឹង ១២ ៧៧០ ហិកតា ៩៥ អា ១១ ស
- ចុះបញ្ជីពីការផ្ទេរសិទ្ធិ បានចំនួន ២៨ ៨៩៤ ប័ណ្ណ
- ចុះបញ្ជីសិទ្ធិប្រាតិភោគ បានចំនួន ២១ ៤២៧ ប័ណ្ណ

គ- ការងារដោះស្រាយវិវាទដីធ្លី

គ.១- លទ្ធផលការដោះស្រាយវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី

- ដោះស្រាយបញ្ចប់ចំនួន ៨៥ ករណី ដែលមាន ៣២៦ គ្រួសារ ស្មើនឹងផ្ទៃដីទំហំ ៤៤,៥ ហិកតា
- ច្រានចោលពាក្យបណ្ដឹងបន្ទាប់ពីស៊ើបអង្កេតឃើញថាខុសសមត្ថកិច្ច ចំនួន ៣៧ ករណី
- សុំដកពាក្យបណ្ដឹងចំនួន ១១ ករណី
- បាននិងកំពុងដោះស្រាយចំនួន ៧៣១ ករណី។

គ.២- ការដោះស្រាយវិវាទដីធ្លីដោយក្រុមការងារក្រសួង

- ទទួលពាក្យបណ្ដឹង ចំនួន ៥១១ ករណី
- លទ្ធផលដោះស្រាយសរុបបានចំនួន ១២៣ ករណី ក្នុងនោះដោះស្រាយបញ្ចប់ចំនួន ២៥ ករណី និងបានធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្ដឹង ឬ បង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធចំនួន ៩៨ ករណី។

ឃ- ការងារអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យសុរិយោដី

- បាននិងកំពុងបន្តការត្រួតពិនិត្យតាមដាន គ្រប់គ្រង និងថែទាំលើប្រព័ន្ធ Microsoft Access Database ដែលមានស្រាប់ជាមូលដ្ឋានទិន្នន័យបម្រើក្នុងការងារអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីក្នុងរាជធានី ខេត្តទាំង ២៥
- បាននិងកំពុងអភិវឌ្ឍប្រព័ន្ធព័ត៌មានសុរិយោដីកម្ពុជា (CCIS) ផ្អែកលើកម្មវិធី Free and open-source software (FOSS) សម្រាប់បម្រើការងារចុះបញ្ជីដីធ្លីទាំងមូល។ ជាលទ្ធផល សម្រេចបានប្រមាណ ៩០% និងកំពុងធ្វើការសាកល្បងដាក់បញ្ចូលទិន្នន័យក្បាលដីនៅរាជធានី ខេត្តចំនួន ០៣ គឺ រាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តកំពង់ចាម។

ង- ការងារវាស់វែងសុរិយោដី

- ចុះណែនាំពីការប្រើប្រាស់ឧបករណ៍វាស់វែងទំនើប Total Station និង D-GPS នៅ ២០ រាជធានី ខេត្ត ដែលមានមន្ត្រីចូលរួមសរុបចំនួន ២៨២ នាក់ និងបានចុះសិក្សាកំណត់ទីតាំងដាំបង្គោល និងវាស់វែងបណ្ដាញបង្គោលប្រឹថពីវិភាគលំដាប់ថ្នាក់ទី ៣ ចំនួន ៧៤ បង្គោល និង

បង្គោលពហុកោណគោលចំនួន **២៧៤** បង្គោល គាំទ្រដល់ក្រុមការងារចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធនៅរាជធានី ខេត្ត ចំនួន ១២ ដោយមានមន្ត្រីក្រុមចុះបញ្ជីចូលរួមសរុបចំនួន **១៧១** នាក់

- បានចុះណែនាំពីរបៀបបង្កើតចំណុចផលិតផែនទីរូបថតលើអាកាសនិងការស្រង់ទិន្នន័យក្បាលដីដាច់ដោយដុំមកគូរបញ្ចូលលើផែនទីរូបថតលើអាកាស (Orthophoto) នៅខេត្តព្រះសីហនុ។

**ច- ការងារគ្រប់គ្រងដីធ្លី**

- បានចុះពង្រឹង និងធ្វើបច្ចុប្បន្នភាពលើការងារផ្សព្វផ្សាយទាក់ទងនឹងការងារចុះបញ្ជីដីធ្លីបានចំនួន ១០ ខេត្ត
- បាននិងកំពុងរៀបចំបោះពុម្ពខិតប័ណ្ណស្តីពី "សុវត្ថិភាពកើតមានតាមរយៈការចុះបញ្ជីដីធ្លី" ចំនួន ១១០ ០០០ សន្លឹក។

## ៤.២.ការងារភូមិសាស្ត្រ

**ក- ការផលិត និងការផ្តល់ទិន្នន័យអ័រតូហ្វូតូ ÷** បានផលិតអ័រតូហ្វូតូរូបថតពីលើអាកាសស-ខ្មៅ និងព័ណ៌ធម្មជាតិមាត្រដ្ឋាន ១:៤០០០ នៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ចាម ត្បូងឃ្មុំ កំពត ប៉ៃលិន មណ្ឌលគិរី តាកែវ ព្រៃវែង ព្រះសីហនុ កំពង់ស្ពឺ និងខេត្តព្រះវិហារ បានសរុបចំនួន **១ ១១៨** សន្លឹក ស្មើនឹង **៤ ៩០២** គ.ម.$^{២}$ និងបានផ្តល់ជូនបណ្តាខេត្តខាងលើ ចំនួន **៧៤៦** សន្លឹក ស្មើនឹង **២ ៦៩២** គ.ម.$^{២}$។

**ខ- ការបោះពុម្ពផែនទី ÷** បានបោះពុម្ពប្លង់សុរិយោដី អ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដីមាត្រដ្ឋាន ១:១០០០ ខ្នាត Ao នៅតាមបណ្តាខេត្តមួយចំនួននៅខេត្តក្រចេះ ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង ព្រះវិហារ មណ្ឌលគិរី ស្វាយរៀង កំពង់ចាម ស្ទឹងត្រែង និងខេត្តសៀមរាប សរុបចំនួន **២ ០៤៦** សន្លឹក។

**គ- ការងារចុះស្រង់ទិន្នន័យភូមិសាស្ត្រ ÷** បានវាស់ទីតាំង និងស្រង់នាមភូមិសាស្ត្រ សរុបចំនួន **២ ៨៣៣** ចំណុច នៅខេត្តប៉ៃលិន បាត់ដំបង និងខេត្តបន្ទាយមានជ័យ។

**ឃ- ការវាស់វែង ÷**

- ចុះដាំ និងវាស់វែងបង្គោលប្រឹថពីវិភាគលំដាប់ទី ២ បានចំនួន **១៣** បង្គោល និងទី ៣ បានចំនួន **១៩** បង្គោល និងចុះដាំបង្គោលរយៈកម្ពស់លំដាប់ទី ៣ បានចំនួន **៤៤** បង្គោល និងវាស់វែងបានចំនួន **២០** បង្គោល ស្មើនឹង **៦៩** គ.ម. នៅក្នុងខេត្តកំពង់ធំ និងខេត្តស្វាយរៀង
- បានចុះដាំបង្គោលរយៈកម្ពស់និងបង្គោលទំនាញផែនដីសរុបចំនួន **២៣៦** បង្គោល តាម

ដងផ្លូវសំខាន់ៗទូទាំងប្រទេសកម្ពុជាលើការអនុវត្តគម្រោងការស្តារ និងធ្វើឱ្យប្រសើរឡើងវិញនូវបណ្តាញរយៈកម្ពស់នៅកម្ពុជា។

## ៥-ការងាររៀបចំដែនដី និងនគរូបនីយកម្ម

### ៥.១-ការងារកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់

- បាន និងកំពុងចងក្រងឯកសារដើម្បីកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់។

### ៥.២-ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

- កំពុងរៀបចំផែនទីដីចំណីឆ្នេរសមុទ្រ ផែនការមេគ្រប់គ្រងការអភិវឌ្ឍ និងអភិរក្សកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានរៀបចំសេចក្តីព្រាងផែនទីមគ្គុទេសចរណ៍សម្រាប់ទេសចរណ៍ខេត្តកែប
- បានចុះពិនិត្យ និងតាមដានការសាងសង់ខ្លោងប្រកចូលឆ្នេរ និងការអនុវត្តផែនការកែលម្អតូបកម្សាន្តនៅឆ្នេរឯករាជ្យ ឆ្នេរអូរឈើទាល និងឆ្នេរអូរត្រេះ
- បានរៀបចំបញ្ចប់ផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ បណ្តាញប្រភពទឹក នៅលើកោះរ៉ុង ខេត្តព្រះសីហនុ
- បាននិងកំពុងកែសម្រួលសៀវភៅរបាយការណ៍បច្ចេកទេសស្តីពីផែនការរៀបចំដែនដីតំបន់ឆ្នេរ
- បានរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីតំបន់បឹងព្រៃកទប់
- បានចុះសិក្សាប្លង់គោលប្រើប្រាស់ដីកោះពស់ កោះឬស្សី និងកោះក្របី នៅខេត្តព្រះសីហនុ កោះសេះ និងកោះគី នៅខេត្តកំពត
- បានស្រង់ទិន្នន័យទីតាំងកោះទាំង ៧៥ ក្នុងនោះ ៣៤ កោះ ទទួលបានការវិនិយោគ។

### ៥.៣-ការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

- បានកែសម្រួល ដើម្បីស្នើសុំការអនុម័តពីរាជរដ្ឋាភិបាលផែនការរៀបចំដែនដីថ្នាក់ខេត្ត ចំនួន ០២ គឺនៅខេត្តបាត់ដំបង និងខេត្តព្រះសីហនុ
- បានចុះគាំទ្របច្ចេកទេស ជំរុញតាមដានការកសាងផែនការរៀបចំដែនដី ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន។

### ៥.៤-ការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក និងទីប្រជុំជន

- បានកែសម្រួលសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាបរួច ដើម្បីត្រៀមសុំការអនុម័តពីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

- **បាននិងកំពុងគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជនចំនួន ១៣ ÷** គឺក្រុងព្រះសីហនុ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្រុងកែប ខេត្តកែប ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្រុងព្រៃវែង ទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនអ្នកលឿង ខេត្តព្រៃវែង ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ក្រុងបាវិត ខេត្តស្វាយរៀង ក្រុងកំពង់ចាម ខេត្តកំពង់ចាម ក្រុងសួង ខេត្តត្បូងឃ្មុំ និងទីប្រជុំជនស្រុកចិត្របុរី ខេត្តក្រចេះ
- **ប្លង់បែងចែកតំបន់ប្រើប្រាស់ដីនៅតាមខណ្ឌក្នុងរាជធានីភ្នំពេញ :** បាននិងកំពុងគាំទ្របច្ចេកទេសកសាងប្លង់បែងចែកតំបន់ប្រើប្រាស់ដី និងសន្ទស្សន៍ប្រើប្រាស់ដីនៅតំបន់ខណ្ឌទាំង ៤ កណ្ដាលរាជធានីភ្នំពេញ មានខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន
- **ប្លង់គោលប្រើប្រាស់ដីស្រុកចំនួន ០៦ :** បានចុះគាំទ្របច្ចេកទេស ជំរុញតាមដានការកសាងប្លង់គោលប្រើប្រាស់ដីស្រុកលំផាត់ ស្រុកវឺនសៃ ស្រុកកូនមុំ ខេត្តរតនគិរី និងស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមប៉ាង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

**៥.៥-ការងារកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់**

- បានចុះគាំទ្របច្ចេកទេស ជំរុញតាមដានការកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំស្រអែម និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឃុំជាំតាម៉ៅ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ឃុំល្មៀង ឃុំអញ្ចើម និងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

## ៦-ការងារសំណង់

វិស័យសំណង់បានបង្កើតការងារជាច្រើនជូនប្រជាពលរដ្ឋក្នុងឆ្នាំ ២០១៧ គិតជាមធ្យមប្រមាណពី **២៥៥ ០០០** នាក់ ទៅ **២៦០ ០០០** នាក់/ថ្ងៃ។ ដោយឡែកនៅរាជធានីភ្នំពេញមានចំនួនកម្មករប្រមាណពី **១២៥ ០០០** នាក់ ទៅ **១៣០ ០០០** នាក់/ថ្ងៃ ។ បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ចំនួនកម្មករគិតជាមធ្យមប្រមាណពី **១៨០ ០០០** នាក់ ទៅ **១៨៥ ០០០** នាក់/ថ្ងៃ សម្រាប់ទូទាំងប្រទេស ដោយឡែកនៅរាជធានីភ្នំពេញមានចំនួនកម្មករប្រមាណពី **១៣០ ០០០ នាក់** ទៅ **១៣៥ ០០០** នាក់/ថ្ងៃ គឺមានការកើនឡើងចំនួន ៤០,៥៤%។

តាមរយៈនៃការសិក្សាស្រាវជ្រាវក្នុងឆ្នាំ ២០១៧ នេះ តម្លៃពលកម្មសម្រាប់កម្មករគ្មានជំនាញក្នុង ១ ថ្ងៃ អាចទទួលបានពី **៣៥ ០០០ រៀល** ដល់ **៤០ ០០០** រៀល កម្មករមានជំនាញ និងមេជាងក្នុង ១ថ្ងៃអាចទទួលបានពី **៥០ ០០០ រៀល** ដល់ **៧៥ ០០០** រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុង ១ ខែ អាចទទួលបានប្រាក់បៀវត្សពី ៤០០ ទៅ ២ ៥០០ ដុល្លារ។

៦.១. ទិន្នន័យសំណង់

ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួនសរុប ៣ ០៥២ គម្រោង មានផ្ទៃក្រឡា **១០ ៧៤៦ ២១៩** ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៦ ៤២៨ ៧៩៤ ១៧៩** ដុល្លារ បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៦ មានចំនួន **២ ៤០៥ គម្រោង** មានផ្ទៃក្រឡាសាងសង់សរុបចំនួន **១១ ៤៤៤ ៧៣៦** ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ៥ **២៥៦ ១២០ ៧០៤** ដុល្លារ គឺមានការកើនឡើងចំនួន **២២,៣១ %** ដែលក្នុងនោះ÷

- ក. <u>សមត្ថកិច្ចក្រសួង:</u> មានចំនួនសរុប **២៣៦** គម្រោង ដែលមានផ្ទៃក្រឡាសរុបចំនួន ៨ ៣២៥ ៨៤២ ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៥ ៨៩៣ ៤៩៨ ៥២០** ដុល្លារ បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៦ មានចំនួន ៣៤៤ គម្រោង ផ្ទៃក្រឡាសំណង់សរុបចំនួន **១០ ០៣៧ ២៨៣** ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៤ ៧៧៦ ៧៦៤ ៩៣០** ដុល្លារ គឺមានការកើនឡើងចំនួន **២៣,៣៧ %**។
- ខ. <u>សមត្ថកិច្ចសាលារាជធានី-ខេត្ត:</u> មានចំនួនសរុប ២ ៨១៦ គម្រោង ដែលមានផ្ទៃក្រឡាចំនួន **២ ៤២០ ៣៧៧** ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៥៣៥ ២៩៥ ៦៥៩** ដុល្លារ បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៦ មានចំនួន ២ ០៦១ គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន **១ ៤០៧ ៤៥៣** ម$^២$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ **៤៧៩ ៣៥៦ ២៧៤** ដុល្លារ គឺមានការកើនឡើងចំនួន **១១,៦៦ %**។

+ *<u>បញ្ជាក់</u> ÷*

- *សំណង់លំនៅឋានសរុបក្នុងឆ្នាំ ២០១៧ មានចំនួន **២ ២៩១ គម្រោង** មានផ្ទៃក្រឡាសរុបចំនួន **៥ ៥៦៥ ១៩១** ម$^២$ មានទុនវិនិយោគ **២ ២៣០ ៦៥៤ ៧១៩** ដុល្លារ។*
- *គម្រោងអគារខ្ពស់ៗចាប់ពី ៥ ជាន់ឡើងទៅនៅរាជធានីភ្នំពេញសរុបក្នុងឆ្នាំ ២០១៧ មានចំនួន **១៨៨** គម្រោង (គិតចាប់ពីអនុវត្តរហូតដល់ឆ្នាំ ២០១៧ មានចំនួន **៩៧៩** គម្រោង)។*
- *សំណង់នៅទូទាំងប្រទេសគិតចាប់តាំងពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៧ បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន **៣៩ ៩០៣** គម្រោង ដែលមានផ្ទៃក្រឡាសំណង់សរុបចំនួន **១០២ ២៣៤ ៧៦៥** ម$^២$ និងតម្លៃប៉ាន់ស្មានទុនវិនិយោគសរុបប្រមាណ **៣៧ ៧៧១ ៦០៣ ៩១១** ដុល្លារ។*

៦.២. ការចុះបញ្ជីក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ និងការផ្តល់វិញ្ញាបនបត្ររូបវន្តបុគ្គលសិក្សាគម្រោងប្លង់

ក. <u>ការផ្តល់វិញ្ញាបនបត្រជូនក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់</u>÷ បានចេញ

វិញ្ញាបនបត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់បានចំនួនសរុប **២៧៥** ក្រុមហ៊ុន បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៦ ដែលមានចំនួន **៣៣៤** ក្រុមហ៊ុន គឺមានការថយចុះចំនួន **៥៩** ក្រុមហ៊ុន ស្មើនឹងថយចុះ **១៧,៦%** ក្នុងនោះ÷

+ បានចុះបញ្ជីក្រុមហ៊ុនក្នុងស្រុកចំនួន **១៧៣** ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនសាងសង់ចំនួន **១៦៥** ក្រុមហ៊ុន និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ចំនួន ០៨ ក្រុមហ៊ុន
+ បានចុះបញ្ជីក្រុមហ៊ុនបរទេសចំនួន **១០២** ក្រុមហ៊ុន ដែលក្នុងនោះក្រុមហ៊ុនសាងសង់ **៩៧** ក្រុមហ៊ុន និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ចំនួន ០៥ ក្រុមហ៊ុន។

គិតចាប់តាំងពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៧ ការចុះបញ្ជីក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់បានចំនួន **២ ១១៣** ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនដែលនៅមានសុពលភាពបច្ចុប្បន្នមានតែចំនួន **១ ០៤៧** ក្រុមហ៊ុន។

ខ.<u>ការផ្តល់វិញ្ញាបនបត្ររូបវន្តបុគ្គលសិក្សាគម្រោងប្លង់</u> ÷ រូបវន្តបុគ្គលដែលបានមកចុះបញ្ជីមានចំនួន **៤៥ រូប** ក្នុងនោះស្ថាបត្យករមានចំនួន **២៧ រូប** វិស្វករមានចំនួន **១៨ រូប** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលមានចំនួន **៥៤ រូប** មានការថយចុះចំនួន **០៩ រូប** ស្មើនឹងការថយចុះ **១៦,៦** %។

សរុបតាំងពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៧ រូបវន្តបុគ្គលសិក្សាគម្រោងប្លង់មានចំនួន **១៦៧** រូប ក្នុងនោះមានស្ថាបត្យករចំនួន **១១៧** រូប (ស្ថាបត្យករបរទេសចំនួន ០៣ រូប និងវិស្វករចំនួន ៥០ រូប)។

## ៦.៣. ការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ និងបិទការដ្ឋានសាងសង់ដែលជាសមត្ថកិច្ចក្រសួង

- បានផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់បានចំនួន **១៣៥** គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ឆ្នាំ ២០១៧ បានផ្តល់ចំនួន **១ ៤៧២** គម្រោង)
- បានផ្តល់លិខិតអនុញ្ញាតបិទការដ្ឋានសាងសង់បានចំនួន **៩៣** គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ឆ្នាំ ២០១៧ បានផ្តល់ចំនួន **៥៥១** គម្រោង)
- បានផ្តល់លិខិតអនុញ្ញាតជួសជុលចំនួន ០៩ គម្រោង (គិតចាប់តាំងពីអនុវត្តមកដល់ឆ្នាំ ២០១៧ បានផ្តល់ចំនួន **១៤៦** គម្រោង)។

## ៦.៤. ការងារដោះស្រាយវិវាទពាក់ព័ន្ធនឹងការងារសាងសង់ និងផ្អាកការដ្ឋាន

- បានទទួលពាក្យបណ្តឹងទាក់ទងវិវាទពាក់ព័ន្ធនឹងការងារសាងសង់សរុបចំនួន **៦០ ករណី** ក្នុងនោះបានដោះស្រាយបញ្ចប់ជាស្ថាពរចំនួន **១៤** ករណី បញ្ជូនទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម

សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៦ ករណី បញ្ជូនទៅទៅស្ថាប័នតុលាការចំនួន ០៣ ករណី កំពុងបន្តដោះស្រាយចំនួន ៣៧ ករណី

- បានផ្អាកការដ្ឋានចំនួន ០៤ លើក។

### ៦.៥. ការងារសាងសង់

- បានសិក្សាគម្រោងប្លង់អគារស្នាក់នៅរបស់សាលានាយទាហានសកម្ម (ត្បាតពង) ស្ថិតនៅភូមិពោធិ៍ ឃុំដំណាក់រាំង ស្រុកឧត្តុង ខេត្តកំពង់ស្ពឺ និងកំពុងដំណើរការសាងសង់បញ្ចប់
- បានចុះសិក្សានិងស្រង់ទិន្នន័យទីតាំងដីសួនទំហំសរុប ២១២ ៥៥៣ ម៉$^{២}$ និងបានសិក្សាប្លង់សួនសែនមនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចប់ជាស្ថាពរ ហើយនឹងចាប់ដំណើរការសាងសង់នៅខែមករា ឆ្នាំ២០១៨។

### ៦.៦. ការងារគណៈស្ថាបត្យករកម្ពុជា

- ទទួលបានស្ថាបត្យករចុះបញ្ជីបានចំនួន **៧៥** នាក់ (ស្ត្រី ០៥ នាក់ និងបរទេសចំនួន ០៣ នាក់ ក្នុងនោះជនជាតិម៉ាឡេស៊ី ០១ នាក់ និងសិង្ហបុរី ០២ នាក់)
- ទទួលប្រាក់វិភាគទានប្រចាំឆ្នាំពីស្ថាបត្យករចុះបញ្ជីបានចំនួន **៣៣** នាក់។

## ៧-ការងារលំនៅឋាន

### ៧.១- ការងារលំនៅឋាន

- បានសហការជាមួយក្រុមហ៊ុន Arakawa ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋដែលជាម្ចាស់ចំណែកឯកជនចំនួន **៤៩២** គ្រួសារ នៃអគារប៊ូឌីញ "ស" ប្រកបដោយជោគជ័យ បញ្ចៀសបាននូវហានិភ័យជាយថាហេតុនៃគ្រោះថ្នាក់ដោយអគារប៊ូឌីញ ស មានសភាពចាស់ទ្រុឌទ្រោមខ្លាំង ហើយប្រជាពលរដ្ឋទាំង ៤៩២ គ្រួសារទទួលបាននូវប្រាក់ថ្លៃខ្ពស់ និងបានទៅតាំងទីលំនៅថ្មីស្របតាមបំណងប្រាថ្នារៀងៗខ្លួនប្រកបដោយការពេញចិត្ត
- បានសហការជាមួយក្រុមហ៊ុន Worldbridgeland Co., Ltd. សាងសង់លំនៅឋានតម្លៃសមរម្យចំនួន ២ ២៩៧ ខ្នង លើផ្ទៃដីទំហំ ២៤ ហិកតា ស្ថិតនៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល
- បានសហការជាមួយក្រុមហ៊ុន B & BM Development Co., Ltd. សាងសង់លំនៅឋានតម្លៃសមរម្យចំនួន ៥ ៣៤០ ខ្នង នៅលើផ្ទៃដីទំហំ ៨២ ហិកតា ស្ថិតនៅភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្ដាល

- បានសហការជាមួយក្រុមហ៊ុន Arakawa សាងសង់លំនៅឋានតម្លៃសមរម្យ ចំនួន ២ ០០០ បន្ទប់ស្នាក់នៅ លើផ្ទៃដីទំហំ ១៣ ៦៨០ ម៉ែត្រក្រឡា ស្ថិតនៅភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
- បានទទួលការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ដែលបានសហការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានចុះពិនិត្យការងារសាងសង់ផ្ទះគំរូដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅខេត្តសៀមរាប និងខេត្តបាត់ដំបងសរុបចំនួន ០៨ លើក
- បានសហការជាមួយអាជ្ញាធរខេត្តបាត់ដំបង កំពង់ចាម រតនគិរី មណ្ឌលគិរី បន្ទាយមានជ័យ ស្វាយរៀង និងខេត្តត្បូងឃ្មុំ ក្នុងការចុះប្រមូលទិន្នន័យ ស្រាវជ្រាវសម្ភារសំណង់ និងតម្លៃពលកម្មសរុបចំនួន ១៥ លើក
- បានសហការជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំ ចុះត្រួតពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាលសាលាខេត្តត្បូងឃ្មុំ និងមន្ទីរជុំវិញខេត្ត ចំនួន ២២ លើក
- បានសហការជាមួយអាជ្ញាធរខេត្តព្រះសីហនុ ត្បូងឃ្មុំ និងខេត្តក្រចេះ ក្នុងការចុះសិក្សាតំបន់ដែលរងគ្រោះដោយទឹកជំនន់ និងខ្យល់កន្ត្រាក់នៅស្រុកស្ទឹងហាវ ស្រុកកំពង់សិលា និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងស្រុកចិត្របុរី ខេត្តក្រចេះ ជ្រើសរើសទីតាំងសមស្រប ដើម្បីសាងសង់លំនៅឋាន ដែលធន់នឹងគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់
- បានសហការជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំ ក្នុងការចុះប្រមូលទិន្នន័យ ដើម្បីរៀបចំផែនការអភិវឌ្ឍលំនៅឋាន នៅទីប្រជុំជនស្រុកមេមត់ ស្រុកអូររាំងឪ ក្រុងសួង និងឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ
- បានសហការជាមួយអាជ្ញាធរខេត្តបាត់ដំបងក្នុងការចុះស្រង់ទិន្នន័យ ដើម្បីកសាងផែនទីទីតាំងតំបន់សំណង់បណ្ដោះអាសន្ន និងសហគមន៍ប្រជាជនក្រីក្រ ចំនួន ៧៦៩ ខ្នងផ្ទះ នៅក្រុងបាត់ដំបង។

## ៧.២- កម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

- បានពិនិត្យឈ្មោះអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ចំនួន ៣២ គ្រួសារ និងណែនាំអំពីនីតិវិធីថ្មី នៃការទទួលបានដីសម្បទានសង្គមកិច្ច

- បានស្អែនប្រវត្តិរូប ផ្ទៀងផ្ទាត់ និងកាត់បញ្ជីឈ្មោះអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ បានចំនួន ១០ ១៣៩ គ្រួសារ ទាំង ១៧ ជំហាន ក្នុងឆ្នាំ២០១០-២០១៣ ដែលទទួលបានពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមខេត្តគោលដៅទាំង ១៦ (ខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ព្រះវិហារ សៀមរាប កំពង់ធំ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កោះកុង ព្រះសីហនុ កំពង់ស្ពឺ កំពត ឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ)
- បានបញ្ជូនបញ្ជីឈ្មោះដែលបានស្នើសុំសម្បទានដីសង្គមកិច្ចរបស់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារចំនួន **១៣ ២៤៧** គ្រួសារ ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី ក្នុងខេត្តគោលដៅទាំង ១៦ ដើម្បីអនុវត្តការងារបន្ត
- បានពិនិត្យឈ្មោះគ្រួសារយោធិន និងនគរបាលចំនួន ២០០ គ្រួសារ ដែលមានឈ្មោះទទួលបានដីសម្បទានសង្គមកិច្ច និងផ្ទះនៅខេត្តស្វាយរៀង
- បានចុះពិនិត្យ និងធ្វើបច្ចុប្បន្នភាពដីបម្រុងទុក សម្រាប់គោលដៅសម្បទានដីសង្គមកិច្ចក្នុងខេត្តគោលដៅទាំង ១៣ គឺខេត្តកំពង់ស្ពឺ បាត់ដំបង ពោធិ៍សាត់ ឧត្តរមានជ័យ មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ សៀមរាប កំពង់ឆ្នាំង ព្រះសីហនុ និងខេត្តកោះកុង មានលទ្ធផលដូចខាងក្រោម÷
    - ផ្ទៃដីបម្រុងទុកដែលនៅសល់សម្រាប់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ សរុបមានទំហំ ១៤ ១០១,៧៥ ហិកតា ក្នុងនោះផ្ទៃដីបានធ្វើអនុបយោគរួច មានទំហំ ៨ ៥២៦,១៩ ហិកតា និងផ្ទៃដីមិនទាន់ធ្វើអនុបយោគ មានទំហំ ៥ ៥៧៥,៥៦ ហិកតា
    - ផ្ទៃដីចូលទន្ទ្រានកាន់កាប់សរុបមានទំហំ ១៥ ៤៥៤,៧ ហិកតា ក្នុងនោះការទន្ទ្រានលើផ្ទៃដីដែលបានអនុបយោគរួចហើយមានទំហំ ៦ ៣៥៤,៦៥ ហិកតា និងទន្ទ្រានលើផ្ទៃដីដែលមិនទាន់ធ្វើអនុបយោគមានទំហំ ៩ ១០០,០៥ ហិកតា និងគ្រួសារដែលចូលទន្ទ្រានមានចំនួន ១ ៤១៧ គ្រួសារ។
- ចុះពិនិត្យស្ថានភាពទីតាំងដី ០១ កន្លែង ដែលសាលាខេត្តឧត្តរមានជ័យ ស្នើសុំប្តូរទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៩៥៤ ហិកតា នៅសង្កាត់កូនក្រៀល ក្រុងសំរោង មកទីតាំងថ្មីមានទំហំ ២ ៦១១ ហិកតា ស្ថិតនៅឃុំពង្រ និងឃុំចុងកាល់ ស្រុកចុងកាល់ (សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទន្លេស្ទឹងហ្គើនខេន ដែលបានប្រគល់ជូនរដ្ឋវិញទំហំ ៦ ១៦៤,៨៣ ហិកតា)
- ចុះពិនិត្យការធ្វើបច្ចុប្បន្នភាពអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារចំនួន ៦១ គ្រួសារ ដែលបានតាំងទីលំនៅជាអចិន្ត្រៃយ៍នៅលើទីតាំងដីសម្បទានសង្គមកិច្ចស្ថិតនៅភូមិប្រហាល ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដើម្បីរៀបចំជាឯកសារសម្រាប់ការស្នើសុំចេញប័ណ្ណកម្មសិទ្ធិ។

**៧.៣- ការអភិវឌ្ឍតាមបណ្តោយព្រំដែនក្នុងខេត្តព្រះវិហារ ឧត្តរមានជ័យ ស្វាយរៀង និងខេត្តស្ទឹងត្រែង**

- បានរៀបចំផែនទី និងចំណុចនិយាមកាដីឡូត៍លំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងសម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដែលឈរជើងការពារនៅតាមបណ្តោយព្រំដែនក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង
- បានបញ្ចប់ការងារសាងសង់ផ្ទះរួចរាល់ ១០០% តាមផែនការឆ្នាំ ២០១៦ ចំនួន ៥៥០ ខ្នង (ខេត្តព្រះវិហារ ចំនួន ២៥០ ខ្នង និងខេត្តឧត្តរមានជ័យចំនួន ៣០០ ខ្នង) និងចំនួន ៣៨ ខ្នងនៅខេត្តឧត្តរមានជ័យ ដោយសហការជាមួយអគ្គិសនីកម្ពុជា
- បានបញ្ចប់ការងារសាងសង់ផ្ទះជូនយោធិន និងនគរបាល ក្នុងគម្រោងប្រចាំឆ្នាំ ២០១៧ ចំនួន **៣៦៧** ខ្នង រួចរាល់ ១០០% ក្នុងនោះនៅខេត្តស្វាយរៀង ចំនួន ២០០ ខ្នង ខេត្តឧត្តរមានជ័យចំនួន ៩៣ ខ្នង ខេត្តស្ទឹងត្រែង ចំនួន ៥០ ខ្នង និងខេត្តព្រះវិហារ ចំនួន ២៤ ខ្នង ។

**៧.៤- កម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ**

- បានផ្តល់ការណែនាំពីនីតិវិធី នៃការដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច ជូនតំណាងប្រជាពលរដ្ឋបាន ០៣ លើក
- បានចុះពិនិត្យនិងបញ្ចប់ការដោះស្រាយសម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋចំនួន ០៧ គ្រួសារ ក្នុងចំណោម **២៥៣** គ្រួសារ ស្ថិតនៅតំបន់ភ្នំខ្នុរ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំពុំទាន់ទទួលបានដីសម្បទានសង្គមកិច្ច
- បានចុះពិនិត្យស្ថានភាពដីជាក់ស្តែង និងប្រជុំពិភាក្សាជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត លើសំណើរបស់ប្រជាពលរដ្ឋនៅខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ចំនួន ១៧៣ គ្រួសារ ស្នើសុំសម្បទានដីសង្គមកិច្ចនៅក្នុងឃុំប៊ូស្រា និងឃុំពូជ្រៃ ក្នុងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
- បានចុះពិនិត្យចំនួន ២ លើក លើទីតាំងដីសម្បទានសង្គមកិច្ចទំហំ ៤ ០០០ ហិកតា ស្ថិតនៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ តាមការស្នើសុំពីលោកស្រី លី សារ៉ស់ និងលោក កែវ សុខន តំណាងប្រជាពលរដ្ឋចំនួន ៤៨២ គ្រួសារ។

**៧.៥- គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ២ (LASED II)**

- បានចុះពិនិត្យ ផ្ទៀងផ្ទាត់ និងប្រមូលឯកសារកិច្ចសន្យាអ្នកទទួលដីនៅខេត្តកំពង់ធំ (ឃុំទីពោ តំបន់១ និង២) ចំនួន **៧៧៦** ច្បាប់ ខេត្តកំពង់ឆ្នាំង (ភូមិសំបុកគ្រៀល ភូមិខ្សាច់ស ភូមិសុខសែនជ័យ និងភូមិគិរីអភិវឌ្ឍន៍) ចំនួន ៨៣៤ ច្បាប់ នៅក្នុងចំណោម ៨៩៣ គ្រួសារ

- បានរៀបចំកំណត់លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងរៀបចំដើម្បីធ្វើអត្តសញ្ញាណកម្មដីក្នុងទីតាំងដីឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ
- បានចុះបញ្ជីដីធ្លីជាប្រព័ន្ធដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិដល់សម្បទានិករបស់គម្រោងក្នុងឃុំទីពោ តំបន់ ១ ស្រុកសន្ទុក ខេត្តកំពង់ធំ ចំនួន ៤៧៦ គ្រួសារ និងឃុំសំបុក និងឃុំចង្រ្កង់ ស្រុកចិត្របុរី ខេត្តក្រចេះ ចំនួន ៨៨៥ គ្រួសារ (ឃុំសំបុក ៣៣១ គ្រួសារ និងឃុំចង្រ្កង់ ៥៥៤ គ្រួសារ)
- បានរៀបចំតារាងធ្វើបច្ចុប្បន្នភាពសម្បទានិកទាំង ១៣ ទីតាំង និងរៀបចំតារាងត្រួតពិនិត្យ និងវាយតម្លៃដើម្បីគ្រប់គ្រងភាពរីកចម្រើនប្រចាំត្រីមាសដែលមានសម្បទានិកចំនួន ២ ៩៨៣ គ្រួសារបានរស់នៅលើដីដែលបានបែងចែក ២ ២១៣ គ្រួសារ បានបង្កបង្កើនផលលើដីកសិកម្មទាំង ១៣ ទីតាំង (លើកលែងឃុំដូងដែលជាទីតាំងថ្មី)
- បានរៀបចំសម្អាតបន្ថែមលើដីកសិកម្មទំហំ ១ ៣៤០ ហិកតា និង ២ ៧៩៦ ហិកតាទៀត បានដាំដុះដំណាំប្រចាំឆ្នាំ និងដាំដំណាំរយៈពេលវែង
- បានផ្តល់អង្ករពលកម្មចំនួន **៧៨ ៤៧០** គីឡូក្រាម ជូនសម្បទានិកចំនួន ៨៥៧ គ្រួសារ ដោយក្នុងនោះ៣៩៣ គ្រួសារ ក្នុងឃុំរស្មីសាមគ្គី ទទួលបានកញ្ចប់ចាប់ផ្តើមលំនៅឋាន និង ៣៩៨ គ្រួសារ ទទួលបានកញ្ចប់ចាប់ផ្តើមកសិកម្មពីអង្គការ LWD GIZ/ILF និងសប្បុរសជន
- បានផលិតខិតប័ណ្ណព័ត៌មាន (Factsheet) ស្តីពីគម្រោងចំនួន ១ ០០០ សន្លឹក (ជាភាសាខ្មែរ និងអង់គ្លេស) ថតសម្លេងដាក់ស៊ីឌីស្តីពីតួនាទី និងកាតព្វកិច្ចរបស់សម្បទានិក និងបែងចែកតាមខេត្តគោលដៅរបស់គម្រោងដើម្បីផ្សព្វផ្សាយបន្ត ព្រមទាំងបណ្តុះបណ្តាល និងណែនាំពីការងារយុទ្ធសាស្រ្តទំនាក់ទំនងរបស់គម្រោង
- បានសម្របសម្រួល និងណែនាំអំពីនីតិវិធីនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដីនៅក្នុងឃុំដូង ស្រុកប្រាសាទបល្ល័ង ខេត្តកំពង់ធំ ដែលមានសមាសភាពចូលរួមចំនួន ០៨ នាក់ ស្ត្រី ០២ នាក់
- បានចូលរួមពិនិត្យដំណើរការការងារចុះធ្វើអត្តសញ្ញាណកម្មដី ផែនទី និងចំណាត់ថ្នាក់ដីរដ្ឋលម្អិតនៅឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ និងធ្វើបច្ចុប្បន្នភាពតារាងត្រួតពិនិត្យ និងវាយតម្លៃប្រចាំត្រីមាសទី ១ និងត្រីមាសទី ២ ឆ្នាំ ២០១៧ ក្នុងទីតាំងទាំង ៣ តំបន់នៅខេត្តកំពង់ធំ
- បានចុះណែនាំអំពីការធ្វើបច្ចុប្បន្នភាពស្ថានភាពរស់នៅ និងការប្រើប្រាស់ដីរបស់សម្បទានិកសម្រាប់ចុះស្រង់ព័ត៌មានជាក់ស្តែងក្នុងឃុំគោលដៅ នៅខេត្តកំពង់ធំ ត្បូងឃ្មុំ និងខេត្តក្រចេះ
- បានចុះពិនិត្យការចុះស្រង់ទិន្នន័យបច្ចុប្បន្នភាពលម្អិតរបស់សម្បទានិកក្នុងខេត្តត្បូងឃ្មុំ ដោយក្នុងនោះសម្រេចបាន ១៥០ គ្រួសារ ស្មើនឹង ៣០០ ឡូត៍ដី ក្នុងចំណោម ២៥០ គ្រួសារ

- បានប្រមូលតារាងទិន្នន័យបឋម ស្តីពីស្ថានភាពរស់នៅ និងប្រើប្រាស់របស់សម្បទានិកស្ថិតនៅ ភូមិស្រែលើសែនជ័យ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន ២៥០ គ្រួសារ
- បានចុះត្រួតពិនិត្យ និងតាមដានការងារសាងសង់ផ្ទះស្នាក់នៅរបស់គ្រូបង្រៀន និងគិលានុ-បដ្ឋាយិកា នៅខេត្តកំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តក្រចេះ សរុបចំនួន ១១ ខ្នង សម្រេចបាន ២៦,៤% និងអគារសហគមន៍នៅខេត្តក្រចេះ ១ ខ្នង សម្រេចបាន ១០%
- បានចុះសិក្សាឋានលេខា និងប្រមូលទិន្នន័យពាក់ព័ន្ធផ្សេងៗ នៃគម្រោងកែលម្អផ្លូវមេក្រួសក្រហម ចូលទីតាំងដីសម្បទានសង្គមកិច្ចឃុំទីពោ (តំបន់ ១ និង ២) ប្រវែងសរុប ១១ គីឡូម៉ែត្រ។

## ៨-ការងារយេនឌ័រ

- បានរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងការចុះពិនិត្យតាមដានការអនុវត្តការងារយេនឌ័រនៅតាមបណ្តារាជធានី ខេត្តចំនួន **១៣** លើក សិក្ខាកាមចូលរួមសរុប **១ ០៧៣** នាក់ (ស្ត្រី ៨៨១ នាក់) ដែលក្នុងនោះរួមមាន ÷
    - បានចុះតាមដានត្រួតពិនិត្យការអនុវត្តអនុសញ្ញាស៊ីដ ៥២ ចំណុច ការបញ្ជ្រាបយេនឌ័រ និងដីធ្លី ការផ្សព្វផ្សាយអនុសាសន៍ ៦ ចំណុចរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដល់មន្ត្រីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ១១ គឺនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរយោដីរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កែប ព្រៃវែង កណ្តាល កំពត តាកែវ ត្បូងឃ្មុំ កំពង់ស្ពឺ និងខេត្តកោះកុង ដែលមានសមាជិកចូលរួមសរុបចំនួន **៣៩៣** នាក់ (ស្ត្រី ២២៥ នាក់)
    - បានរៀបចំសិក្ខាសាលា ស្តីពីការបញ្ជ្រាបយេនឌ័រនិងដីធ្លី នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានអ្នកចូលរួមសរុបចំនួន **១១០** នាក់ (ស្ត្រី ៨៦ នាក់)
    - បានរៀបចំអបអរសាទរទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ ២០១៧ ខួបទី ១០៦ ក្រោមប្រធានបទ "ស្ត្រីដើម្បីសុខសន្តិភាព និងវឌ្ឍនភាព" ដែលមានអ្នកចូលរួមសរុប **៥៧០** នាក់។

## ៩-ការងារសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ

ក្រសួងបាននិងកំពុងបន្តសហការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលរួមមាន÷

**ក. ការងាររដ្ឋបាលដីធ្លី:** (1)-បានសហការជាមួយសមាគមអ្នកច្បាប់ជប៉ុន Shiho Shohi លើការងារចុះបញ្ជីអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រម

រដ្ឋប្បវេណី គាំទ្រដោយអង្គការ JICA និង (2)-គម្រោងស្តារនិងធ្វើឱ្យប្រសើរឡើងវិញនូវបណ្តាញរយៈកម្ពស់នៅកម្ពុជា ដែលគាំទ្រដោយរដ្ឋាភិបាលវៀតណាម។

ខ. **ការងាររៀបចំដែនដី** : (1)-គម្រោងកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ នៃកម្មវិធីរបស់ក្រសួង និងកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ គាំទ្រដោយ ADB (2)-សហការជាមួយក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូននៃសាធារណរដ្ឋកូរ៉េ និងជប៉ុន ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម និង (3)-សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការចុះដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទំនប់ទឹកដូនទ្រី នៅខេត្តបាត់ដំបង និងទន្លេវៃគោ នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។

គ. **ការងារសំណង់** : (1)-សមាគមអ្នកសាងសង់កម្ពុជា (2)- EuroCham Cambodia លើការងាររៀបចំបទដ្ឋានបច្ចេកទេសសំណង់អគារ។

ឃ. **ការងារលំនៅឋាន** : (1)-សម្ព័ន្ធភាពអាស៊ីដើម្បីសិទ្ធិលំនៅឋាន (ACHR) លើការងារលំនៅឋានសាធារណៈនៅកម្ពុជា (2)-មូលនិធិអភិវឌ្ឍន៍សហគមន៍ (CDF) លើការងារលំនៅឋានសាធារណៈនៅកម្ពុជា (3)-អង្គការ Caritas ក្នុងការរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសលំនៅឋានដែលធន់នឹងខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ទឹកជំនន់ និងការបាក់ដី (4)-អង្គការ NGO Forum (5)-ក្រុមហ៊ុនវើលប្រ៊ីដ៍ឡិន ខូអិលធីឌី (Worldbridgeland Co.,Ltd.) និងក្រុមហ៊ុន B & BM Development Co.,Ltd. លើការងារសាងសង់លំនៅឋានដែលមានតម្លៃសមរម្យនៅកម្ពុជា (6)-ក្រុមហ៊ុន ARAKAWA Co.,Ltd. លើគម្រោងអគារសហកម្មសិទ្ធិប៊ូឌីញ " ស " និងគម្រោងសាងសង់លំនៅឋានតម្លៃសមរម្យ (7)-គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED II) គាំទ្រដោយធនាគារពិភពលោក និង (8)-អង្គការ GIZ លើគម្រោងលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខសៀង ILF។

## ១០-ការងារអភិវឌ្ឍសេដ្ឋកិច្ច កិច្ចការវិនិយោគ

- បានសម្របសម្រួល និងគាំទ្រគម្រោងស្នើសុំវិនិយោគចំនួន **៣៧** ក្រុមហ៊ុន លើវិស័យឧស្សាហកម្ម និងកម្មន្តសាល ដែលបានធ្វើការចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានទុនវិនិយោគចំនួន **១៨២ ៣៨៣ ៤៦៥** ដុល្លារ និងអាចបង្កើតការងារបានចំនួន **៥០ ៣២៩** កន្លែង។

## ១១-ការងារលទ្ធកម្ម

- គម្រោងលទ្ធកម្មសរុបសម្រាប់ឆ្នាំ ២០១៧ មានចំនួន **៣១** គម្រោង ក្នុងនោះ÷
  - បានអនុវត្តនីតិវិធីទូទាត់ចំនួន **២៧** គម្រោង

• កំពុងអនុវត្តនីតិវិធីលទ្ធកម្មលើការងារអគារមជ្ឈមណ្ឌលឯកសារ ចំនួន ០១ គម្រោង
• គម្រោងដែលមិនអាចអនុវត្តបានចំនួន ០៣ គម្រោង។

## II-ទិសដៅការងារបន្ត

### ១.ការអភិវឌ្ឍស្ថាប័ន

#### ១.១. ការងារគ្រប់គ្រងមន្ត្រី

- បន្តពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីរាជការក្រោមឱវាទក្រសួង
- រៀបចំបែបបទដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ។

#### ១.២- ការងារផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច

- បន្តជំរុញការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋបាលកណ្តាល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត
- បន្តពង្រឹង និងអនុវត្តការងារថវិកាកម្មវិធីពេញលេញប្រកបដោយតម្លាភាព និងប្រសិទ្ធភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បន្តរួមចំណែកអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជំរុញការបើកផ្តល់ប្រាក់បេសកកម្មរបស់មន្ត្រីតាមប្រព័ន្ធធនាគារ
- បន្តអនុវត្តការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការក្រសួងបានទាន់ពេលវេលាស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល។

#### ១.៣. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

- បើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងសុរិយោដីជំនាន់ទី ៩ និងថ្នាក់បរិញ្ញាបត្ររងរៀបចំដែនដីជំនាន់ទី ៣
- រៀបចំសិក្ខាសាលាស្តីពីខ្លឹមសារសំខាន់ៗ នៃគោលនយោបាយដីធ្លីពាក់ព័ន្ធនឹងអាជ្ញាធរដែនដីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធជុំវិញរាជធានី ខេត្ត ចំនួន ១៥ លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន កំពង់ធំ សៀមរាប ព្រះវិហារ ក្រចេះ ស្ទឹងត្រែង បន្ទាយមានជ័យ ឧត្តរមានជ័យ មណ្ឌលគិរី និងខេត្តរតនគិរី
- បើកវគ្គបំប៉នការងារសំណង់ ការងាររៀបចំដែនដី និងនគរូបនីយកម្ម និងការងារសុរិយោដី និងភូមិសាស្ត្រ ចំនួន ០៣ វគ្គ។

### ១.៤.ការងារសវនកម្ម និងអធិការកិច្ច

- អនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យឯកសារនៃការអនុវត្តចំណូល ចំណាយថវិការដ្ឋ ការប្រមូលចំណូលសេវាសាធារណៈពីសេវាសុរិយោដី និងសេវាសំណង់ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយ-បរិច្ឆេទឆ្នាំ ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធ
- បន្តចុះត្រួតពិនិត្យការងាររដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការងារបច្ចេកទេសសុរិយោដី
- បន្តចុះពិនិត្យស្រាវជ្រាវបណ្តឹងពាក់ព័ន្ធនឹងការងាររដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការងារបច្ចេកទេសសុរិយោដី ព្រមទាំងវិវាទដីធ្លីផ្សេងៗទៀត
- បន្តតាមដានអំពីការអនុវត្តច្បាប់ គោលការណ៍ណែនាំ និងនីតិវិធីលើការងាររដ្ឋបាល និងការងារបច្ចេកទេសសុរិយោដី នៅតាមបណ្តាមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ
- បន្តសហការចុះស្រាវជ្រាវប្រមូលព័ត៌មានជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ ទាក់ទងនឹងការងាររដ្ឋបាលដីធ្លី។

### ១.៥.ការគាំទ្រការងារវិមជ្ឈការ និងវិសហមជ្ឈការ

- សហការជាមួយក្រសួងមហាផ្ទៃ ជំរុញធ្វើប្រតិភូកម្មការចេញលិខិតអនុញ្ញាតសាងសង់ដល់រដ្ឋបាលស្រុកចំនួន ៤៨ បន្ថែមទៀត ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សមស្របអាចទទួលមុខងារនេះបាន
- បន្តត្រួតពិនិត្យមុខងារឡើងវិញ ដើម្បីអនុវត្តនីតិវិធីក្នុងការផ្ទេរមុខងារ និងធនធានឱ្យទៅដល់ថ្នាក់ក្រោមជាតិ
- ចុះតាមដាន និងត្រួតពិនិត្យការផ្តល់សេវាសាធារណៈនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ
- បន្តកិច្ចសហការក្នុងការត្រួតពិនិត្យកែសម្រួលមុខសញ្ញា និងតម្លៃសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

## ២.ការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្ត

- បន្តជំរុញរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំអនុវត្តដែលនៅសេសសល់
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលក្រសួងបានអនុម័តនិងដាក់ឱ្យប្រើប្រាស់។

## ៣.ការផ្តល់សេវាសាធារណៈតាមច្រកចេញចូលតែមួយ

- ប្រជុំតាមដានត្រួតពិនិត្យវឌ្ឍនភាពការងារផ្តល់សេវាសាធារណៈប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលប្រចាំត្រីមាស ស្តីពីនីតិវិធីការផ្តល់សេវាសាធារណៈតាមយន្តការ ច្រកចេញចូលតែមួយដល់មន្ត្រីប្រចាំការនៅច្រកចេញ ចូលតែមួយនៃមន្ទីរដ.ន.ស.ស.រាជធានី ខេត្ត
- បន្តពង្រឹងកិច្ចសម្របសម្រួលលើការងារផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ និងប្រកបដោយ ប្រសិទ្ធភាព
- រៀបចំប្រព័ន្ធគ្រប់គ្រង ទិន្នន័យផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំដំណើរការផ្តល់សេវាចុះបញ្ជីក្រុមហ៊ុន និងសហគ្រាសសាងសង់ តាមប្រព័ន្ធអនឡាញ (Online) និងខិតខំពង្រីកសមត្ថភាពដល់មុខសេវាផ្សេងៗទៀត។

## ៤.ការងាររដ្ឋបាលដីធ្លី

- បន្តជំរុញចេញប័ណ្ណឱ្យបានឆាប់នូវទិន្នន័យសេសសល់ពីការអនុវត្តបទបញ្ជាលេខ ០១ ប.ប. និង ពីការអនុវត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីក្នុងឆ្នាំ ២០១៧
- បន្តជំរុញប្រកាសតំបន់វិនិច្ឆ័យតាមភូមិនៅទូទាំងប្រទេស ដើម្បីឈានទៅសម្រេចតាមផែនការ ឆ្នាំ ២០១៨ ដោយចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធឱ្យសម្រេចបានចំនួន ៤០០ ០០០ ក្បាលដី ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឱ្យបាន ១០ សហគមន៍ និងការចុះបញ្ជីដីរដ្ឋ ពិសេស ដីរដ្ឋជាកម្មវត្ថុនៃសម្បទានសេដ្ឋកិច្ចដែលបានត្រួតពិនិត្យរួចឱ្យបាន ១៥ ម៉ឺនហិកតា និងខិតខំ ជម្រះទិន្នន័យក្បាលដី ចុះបញ្ជីដីដាច់ដោយដុំ
- បន្តកិច្ចសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ពន្លឿនការដោះស្រាយវិវាទដីធ្លី និងគាំទ្រផ្នែក គតិយុត្ត និងបច្ចេកទេសដល់ក្រុមដោះស្រាយវិវាទដីធ្លីរបស់ក្រសួង និងក្រុមចល័ត
- បន្តផលិតអ័រតូហ្វូតូ និងធ្វើបច្ចុប្បន្នភាពទិន្នន័យព្រំប្រទល់រដ្ឋបាល និងបញ្ជីវាយនាមភូមិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជានូវភូមិ ឃុំដែលបានបង្កើតថ្មី
- បន្តចុះប្រមូលទិន្នន័យព្រំប្រទល់រដ្ឋបាលនៅក្នុងខេត្តកំពង់ឆ្នាំង
- បន្តចុះដាំ និងវាស់វែងបង្គោលប្រឹថពីវិភាគ និងបង្គោលរយៈកម្ពស់នៅខេត្តកំពង់ធំ
- បន្តរៀបចំអភិវឌ្ឍបញ្ចប់លើប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យចុះបញ្ជីដីធ្លីដែលមានស្រាប់ពីកម្មវិធី Microsoft Access ទៅកម្មវិធី Open Source ដើម្បីឆ្លើយតបទៅនឹងច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តថ្មីៗ និងដើម្បីពន្លឿនការផ្តល់សេវាចុះបញ្ជីដីធ្លី

- បន្តចុះពង្រឹងការងារវាស់វែង និងការប្រើប្រាស់ឧបករណ៍វាស់វែងទំនើប Total Station និង D-GPS រាជធានី ខេត្ត
- បន្តចុះណែនាំ និងត្រួតពិនិត្យគុណភាពទិន្នន័យវាស់វែងរាជធានី ខេត្ត
- បន្តចុះត្រួតពិនិត្យ និងណែនាំការកសាងឯកសារបច្ចេកទេសវាស់វែងសុរិយោដីក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បន្តជំរុញការបញ្ជូនឯកសារចុះបញ្ជីដីធ្លីដែលបានសម្រេចចុះបញ្ជីនៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត រួច ទៅរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើលេខាចារឹក និងចរន្តការឱ្យបានស្របគ្នានិងស៊ីសង្វាក់គ្នារវាងរដ្ឋបាលសុរិយោដីទាំងបីថ្នាក់
- លើកកម្ពស់ការចូលរួមរបស់ម្ចាស់ដីនិងអ្នកពាក់ព័ន្ធ (ទាំងប្រជាពលរដ្ឋទូទៅ និងស្ថាប័នរដ្ឋនានា) ក្នុងសកម្មភាពអនុវត្តការចុះបញ្ជីដីធ្លី តាមរយៈការផ្សព្វផ្សាយគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដើម្បីបង្កើនការយល់ដឹងលើវិស័យដីធ្លីកាន់តែទូលំទូលាយ ព្រមទាំងបង្កើនជំនឿទុកចិត្តរបស់មហាជនមកលើប្រព័ន្ធចុះបញ្ជីដីធ្លី តាមរយៈការផ្តល់សេវាល្អ តម្លាភាព លឿន និងតម្លៃសមរម្យឆ្ពោះទៅរកវប្បធម៌ នៃការចុះបញ្ជីដីធ្លីមួយប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍបញ្ចប់និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសុរិយោដីកម្ពុជាតាមកម្មវិធី Free Open Source Software ព្រមទាំងដាក់បន្ថែម QR CODE លើសន្លឹកប័ណ្ណកម្មសិទ្ធិទម្រង់ថ្មី។

## ៥.ការងាររៀបចំដែនដី និងនគរូបនីយកម្ម

### ៥.១- ការងារកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងថ្នាក់តំបន់

- បន្តកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ និងតំបន់។

### ៥.២- ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

- បន្តការពារដីចំណីឆ្នេរនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយរៀបចំយុទ្ធសាស្ត្រជាតិសមាហរណកម្មការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ផែនការរៀបចំដែនដីខេត្ត ប្លង់គោលប្រើប្រាស់ដីក្រុង ផែនទីឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងប្លង់គោលប្រើប្រាស់ដីកោះនៅខេត្តទាំង ៤ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- បន្តចុះពិនិត្យ និងតាមដានការសាងសង់ខ្លោងច្រកចូលឆ្នេរ និងការអនុវត្តផែនការកែលម្អតូបកម្សាន្ត នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បន្តសិក្សាប្លង់គោល និងផែនការប្រើប្រាស់ដីកោះរ៉ុង ក្រុងព្រះសីហនុ

- បញ្ចប់ការកែសម្រួលសេចក្តីព្រាងរបាយការណ៍បច្ចេកទេសស្តីពីផែនការរៀបចំដែនដីតំបន់ឆ្នេរសមុទ្រ ដើម្បីសុំការអនុម័តពីរាជរដ្ឋាភិបាល
- បន្តរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បញ្ចប់សេចក្តីព្រាងផែនការប្រើប្រាស់ដីតំបន់បឹងព្រៃកទប់
- បន្តចុះសិក្សាប្លង់គោលប្រើប្រាស់ដីនៅខេត្តទាំង ៤ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា ពិសេសកោះពស់ កោះឫស្សី និងកោះក្របី ខេត្តព្រះសីហនុ កោះសេះ និងកោះតី ខេត្តកំពត។

**៥.៣- ការងារកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត**

- ស្នើសុំការអនុម័តពីរាជរដ្ឋាភិបាលលើផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនការរៀបចំដែនដីខេត្តបាត់ដំបង
- បន្តគាំទ្របច្ចេកទេស និងជំរុញតាមដានការងារកសាងផែនការរៀបចំដែនដីខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន ។

**៥.៤ - ការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក និងទីប្រជុំជន**

- ស្នើសុំការអនុម័តពីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ លើប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប
- បន្តគាំទ្រនិងជំរុញការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ចំនួន ១៣ គឺក្រុងព្រះសីហនុ និងទីប្រជុំជនស្ទឹងហាវ ខេត្តព្រះសីហនុ ក្រុងកែប ខេត្តកែប ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្រុងព្រៃវែង ទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនអ្នកលឿង ខេត្តព្រៃវែង ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ក្រុងបាវិត ខេត្តស្វាយរៀង ក្រុងកំពង់ចាម ខេត្តកំពង់ចាម ក្រុងសួង ខេត្តត្បូងឃ្មុំ និងទីប្រជុំជនស្រុកចិត្របុរី ខេត្តក្រចេះ
- បន្តគាំទ្របច្ចេកទេសលើការកសាងប្លង់បែងចែកតំបន់ប្រើប្រាស់ដី កម្ពស់ និងគម្លាត និងសន្ទស្សន៍ប្រើប្រាស់ដីនៅក្នុងខណ្ឌទាំង ០៤ កណ្តាលរាជធានីភ្នំពេញរួមមាន ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន
- បន្តគាំទ្របច្ចេកទេសលើការកសាងប្លង់គោលប្រើប្រាស់ដីស្រុកលំផាត់ ស្រុកវ៉ឺនសៃ និងស្រុកកូនមុំ ខេត្តរតនគិរី ស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមប៉ាង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

៥.៥ - ការងារកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

- បន្តគាំទ្របច្ចេកទេសលើការរៀបចំផែនការប្រើប្រាស់ដីក្នុងឃុំស្រអែម និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឃុំជាំតាម៉ៅ ឃុំទន្លូង ស្រុកមេមត់ ឃុំល្មៀង ឃុំអញ្ចើម និងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត
- បន្តរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ចំនួន ៩០ ក្នុងក្របខណ្ឌកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

## ៦-ការងារសំណង់

- រៀបចំប្លង់បង្ហាញពីការធ្វើចិញ្ចើមផ្លូវ បង្កាន់ដៃឆ្លងកាត់តាមទីក្រុង ទីប្រជុំជនដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនពិការ និងធ្វើការផ្សព្វផ្សាយដល់គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធដើម្បីអនុវត្ត
- ចងក្រងទិន្នន័យសំណង់ជាប្រព័ន្ធ និងគ្រប់គ្រងការដ្ឋានសាងសង់តាមប្រព័ន្ធភូមិសាស្ត្រ GIS
- បន្តទប់ស្កាត់ការសាងសង់ដោយគ្មាន ឬខុសពីលិខិតអនុញ្ញាត
- បន្តចុះដោះស្រាយវិវាទពាក់ព័ន្ធនឹងការងារសាងសង់តាមបណ្តារាជធានី ខេត្ត
- បន្តបង្កើនប្រសិទ្ធភាពការងារ និងសម្រេចឱ្យបានតាមបរិបថការងារលើការត្រួតពិនិត្យគម្រោងនៃការស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើក បិទការដ្ឋានសាងសង់ ការចុះបញ្ជីប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គល
- ជំរុញការពិនិត្យគម្រោងប្លង់ស្ថាបត្យកម្មដើម្បីផ្តល់លិខិតអនុញ្ញាតសាងសង់ និងប្លង់គ្រឿងបង្គុំសំណង់ ដើម្បីផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់
- ជំរុញការពិនិត្យ និងផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ សាងសង់ និងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- បន្តពង្រឹងនិងសហប្រតិបត្តិការលើសេវាកម្មស្ថាបត្យកម្មជាមួយសេវាកម្មស្ថាបត្យកម្មបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងការងារផ្សេងៗ
- បន្តបញ្ចូលស្ថាបត្យករចុះបញ្ជីជាស្ថាបត្យករគណៈស្ថាបត្យករ និងជាស្ថាបត្យករអាស៊ាន
- ជំរុញការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការកំណត់តម្លៃសេវាស្ថាបត្យកម្ម និងស្តង់ដារស្ថាបត្យកម្ម
- បន្តគាំទ្របច្ចេកទេសដល់ការសាងសង់សួនសែនមនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
- បន្តផ្សព្វផ្សាយឯកសារគតិយុត្ត និងធ្វើការណែនាំស្តីពីការគ្រប់គ្រងវិស័យសំណង់ ដើម្បីជំរុញការងារស្នើសុំ និងផ្តល់លិខិតអនុញ្ញាតបើក បិទការដ្ឋានសាងសង់ លិខិតអនុញ្ញាតជួសជុល ការប្រកប

អាជីវកម្មសំណង់របស់សហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គល និងក្រុមជាងសំណង់នៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត

- បន្តលើកទឹកចិត្ត និងផ្សព្វផ្សាយស្ថាបត្យកម្មដែលមានលក្ខណៈខ្មែរ
- ផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសុវត្ថិភាពក្នុងការដ្ឋានសំណង់។

**៧.ការខារលំនៅឋាន**

- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនក្នុងការអនុវត្ត "គោលនយោបាយលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ" ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋដែលមានចំណូលមធ្យម ចំណូលទាប និងជនងាយរងគ្រោះ
- បន្តសម្របសម្រួលជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីស្រង់ទិន្នន័យ និងកសាងផែនទីទីតាំងសំណង់បណ្តោះអាសន្ន និងសហគមន៍ប្រជាជនក្រីក្រ
- បន្តសហការជាមួយអាជ្ញាធរខេត្តព្រះសីហនុ ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ក្នុងការចុះសិក្សាតំបន់ដែលរងគ្រោះដោយទឹកជំនន់ និងខ្យល់កន្ត្រាក់ ដើម្បីជ្រើសរើសទីតាំងសមស្របសម្រាប់សាងសង់លំនៅឋាន ដែលធន់នឹងគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់
- បន្តសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការចុះប្រមូលទិន្នន័យ ស្រាវជ្រាវសម្ភារសំណង់និងតម្លៃពលកម្ម
- បន្តចុះប្រមូលទិន្នន័យអំពីសេវាកម្មឥណទានលំនៅឋានតម្លៃសមរម្យនៅតាមបណ្តារាជធានី ខេត្ត
- បន្តសហការជាដៃគូអភិវឌ្ឍន៍ ដើម្បីអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យជូនប្រជាពលរដ្ឋមានប្រាក់ចំណូលមធ្យម និងប្រាក់ចំណូលទាប
- បន្តកៀរគរវិនិយោគិនគ្រប់មជ្ឈដ្ឋាន ដើម្បីវិនិយោគលើលំនៅឋានតម្លៃសមរម្យឱ្យកាន់តែមានភាពទូលំទូលាយ និងសំបូរបែប ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ
- បន្តសាងសង់ផ្ទះជូនគ្រួសារយោធិន និងនគរបាលនៅតាមបណ្តោយព្រំដែននៃខេត្តស្ទឹងត្រែង ស្វាយរៀង ឧត្តរមានជ័យ និងខេត្តព្រះវិហារ
- ចុះធ្វើបច្ចុប្បន្នភាពអ្នកទទួលបានសម្បទានដីសង្គមកិច្ចចំនួន ២៥៣ គ្រួសារ នៅឃុំបឹងល្វា ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ
- សហការជាមួយក្រុមការងារខេត្តព្រះវិហារ ដើម្បីចុះធ្វើអត្តសញ្ញាណកម្មដី និងធ្វើផែនទីទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៨ ១៥២ ហិកតា ស្ថិតនៅឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដើម្បីចែកជូនប្រជាពលរដ្ឋចំនួន ១ ១៨៧ គ្រួសារ មកពីខេត្តកំពង់ចាម

- បន្តធ្វើបច្ចុប្បន្នភាពស្ថានភាពរស់នៅ និងការប្រើប្រាស់ដីរបស់សម្បទានិក នៃគម្រោង LASED II ក្នុងខេត្តគោលដៅចំនួន ០២ គឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ
- សិក្សាគម្រោងប្លង់សាងសង់អគារប៉ុស្តិ៍សុខភាពចំនួន ០៥ កន្លែង គឺនៅខេត្តក្រចេះ ០២កន្លែង ខេត្តកំពង់ឆ្នាំង ០១ កន្លែង និងខេត្តកំពង់ធំ ០២ កន្លែង
- ចុះត្រួតពិនិត្យ និងតាមដានការងារសាងសង់អគារស្នាក់នៅរបស់គ្រូបង្រៀន និងគិលានុបដ្ឋាន អគារសហគមន៍ និងគម្រោងខ្ទង់អណ្តូងស្នប់ ក្នុងខេត្តគោលដៅទាំង ៥ គឺ ខេត្តក្រចេះ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ
- ចុះសិក្សាទីតាំងគម្រោងដើម្បីសាងសង់ផ្លូវ និងជួសជុលផ្លូវក្នុងខេត្តគោលដៅចំនួន ៥ នៃគម្រោង គឺ ខេត្តក្រចេះ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ
- បន្តប្រកាសតំបន់វិនិច្ឆ័យក្នុងទីតាំងសម្បទានដីសង្គមកិច្ចដើម្បីចុះបញ្ជី និងចែកប័ណ្ណកម្មសិទ្ធិដល់សម្បទានិក
- បន្តជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងធ្វើអត្តសញ្ញាណកម្មដីក្នុងឃុំដូង ស្ថិតនៅស្រុកប្រាសាទ-បល្ល័ង្គ ខេត្តកំពង់ធំ
- ចុះពិនិត្យផ្ទៀងផ្ទាត់ឯកសារបច្ចេកទេសសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងចងក្រងឯកសារក្នុងខេត្តគោលដៅនៃគម្រោងសម្បទានដីសង្គមកិច្ច
- ចុះសិក្សាឋានលេខា និងប្រមូលទិន្នន័យពាក់ព័ន្ធសម្រាប់គម្រោងជួសជុលផ្លូវដីគម្រោងកែលម្អផ្លូវដី ដែលមានប្រវែងសរុប ៣០០គ.ម. ក្នុងខេត្តគោលដៅទាំង ០៥ ដើម្បីស្ថាបនាជាផ្លូវក្រួសក្រហម
- ចុះសិក្សាលម្អិត និងប្រមូលទិន្នន័យពាក់ព័ន្ធ នៃគម្រោងសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ក្នុងខេត្តគោលដៅនៃគម្រោងសម្បទានដីសង្គមកិច្ច
- រៀបចំពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លីជូនសម្បទានិក ចំនួន ១ ៣៦១ គ្រួសារ ក្នុងនោះ ឃុំទីពោធិ៍បន់ ១ ស្ថិតនៅស្រុកសន្ទុក ខេត្តកំពង់ធំ ចំនួន ៤៧៦ គ្រួសារ ឃុំសំបុក និងឃុំចង្ក្រង់ ក្នុងខេត្តក្រចេះ ចំនួន ៨៨៥ គ្រួសារ។

## ៩.ការងារសមភាពយេនឌ័រ

- បន្តចុះតាមដានការអនុវត្តការបញ្ជ្រាបយេនឌ័រនិងដីធ្លី និងផ្សព្វផ្សាយអនុសាសន៍ ៥២ ចំណុច និងអនុសាសន៍ ០៦ ចំណុចរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** តាមបណ្តាខេត្ត ១១
- រៀបចំពិធីអបអរសាទរទិវាបុណ្យអន្តរជាតិនារី ០៨មីនា ឆ្នាំ ២០១៨។

**១០-ការងារអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចការវិនិយោគ**

- ត្រៀមបោះពុម្ពសៀវភៅទិន្នន័យស្ថិតិផ្លូវការប្រចាំឆ្នាំ ២០១៦
- បន្តកិច្ចការសម្របសម្រួលការងារអនុវិស័យដីធ្លី និងផ្នែកពាក់ព័ន្ធជាមួយដៃគូអភិវឌ្ឍន៍។

**១១-ការងារលទ្ធកម្ម**

- រៀបចំសរុបផែនការលទ្ធកម្មប្រចាំឆ្នាំ ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអនុវត្តកិច្ចលទ្ធកម្មឱ្យបានទាន់ពេលវេលា មានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។

**សេចក្ដីសន្និដ្ឋាន**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបាននូវការងារស្របតាមផែនការដែលដាក់ចេញដោយរាជរដ្ឋាភិបាលលើការងារកែទម្រង់ក្នុងវិស័យដីធ្លី និងសំណង់។ លទ្ធផលដែលសម្រេចបានខាងលើនេះ អាស្រ័យដោយមានការគាំទ្រ និងការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញនូវចក្ខុវិស័យកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដ៏ត្រឹមត្រូវ ច្បាស់លាស់ និងឆ្លើយតបចំគោលដៅទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ។ លទ្ធផលទាំងនេះ ក៏ឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែង និងសាមគ្គីឯកភាពផ្ទៃក្នុងរឹងមាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅគ្រប់ថ្នាក់ និងគ្រប់ផ្នែក ការគាំទ្រនិងកិច្ចសហការល្អពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ថ្នាក់ និងការចូលរួមពីប្រជាពលរដ្ឋនិងគ្រប់មជ្ឈដ្ឋានក្នុងសង្គម៕

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ « ដើម្បីជូនជ្រាប »
- គ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ « ដើម្បីជូនជ្រាប និងសហការអនុវត្ត »
- ឯកសារ-កាលប្បវត្តិ